**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ៥០៥ អនក្រ.តត

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# អនុក្រឹត្យ

ស្តីពី

## ការផ្តល់សមត្ថកិច្ចបន្ថែមជាសារការីដល់មេធាវី នៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៩៥

-យោងតាមភាពចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

**សំរេច**

**មាត្រា ១.~**

តែងតាំងលោក **ប៉ែនសុន សម័យ** សមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជាមាន អត្តលេខ ៥៤ បន្ថែមលើមុខងារប២ច្ចុប្បន្នជា សារការី ដែលហៅថា "**មេធាវីសារការី**" ។

**មាត្រា ២.~**

**មេធាវីសារការី** ជាមន្ត្រីសាធារណៈ ទទួលបាននូវអំណាចសាធារណៈតាមការតែងតាំងដោយអនុក្រឹត្យនេះ ។

**មាត្រា ៣.~**

**មេធាវីសារការី** មានសមត្ថកិច្ចការងារទូទៅក្នុងវិស័យផ្នែកគ្រួសារ ចលនវត្ថុ និងអចលនវត្ថុ ជាអាទិ៍មាន :

ក. ទទួល និងធ្វើ ឬចារឹកបញ្ជាក់ និងប្រថាប់ត្រា នូវលិខិតស្នាមគតិយុត្តិ ឬកិច្ចសន្យាទាំងឡាយដើម្បីជាបន្ទាល់

ពេញលក្ខណៈតាមផ្លូវច្បាប់ ដែលតែងតែមានលិខិតរបស់រាជការអំណាចសាធារណៈ ។

ខ. ធ្វើការបញ្ជាក់លើកាវិយបរិច្ឆេទ ទទួលតំកល់ទុកឯកសារ និងចេញអោយនូវសេចក្ដីដើម ឬសេចក្ដីចម្លងនៃលិខិត ឬកិច្ចសន្យាទាំងឡាយនោះតាមមុខការ ។

គ. កិច្ចការនេះត្រូវពិនិត្យ អានឱ្យអស់សេចក្ដី និងចុះហត្ថលេខានៃគូភាគីនៅចំពោះមុខ ទើប **មេធាវីសារការី** ចុះហត្ថលេខា ប្រថាប់ត្រា ចារឹកនាពេលនោះជាចុងក្រោយ ។

**មាត្រា ៤.៑**

**មេធាវីសារការី** ត្រូវតំកល់ប្រាក់ធានាចំនួន ៦០០.០០០.០០០.០០ ( ប្រាំមួយរយលានរៀល) នៅធនាគារជាតិនៃកម្ពុជាសំរាប់ទទួលខុសត្រូវក្នុងមុខការនេះ ។

**មាត្រា ៥.៑**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

**ចម្លងជូន :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា៥

-ឯកសារ -កាលប្បវត្តិ